# សេចក្តីសម្រេចចិត្ត

# នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ឆ្នាំ២០១៥

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ឆ្នាំ២០១៥ បានដំណើរការរយៈពេលមួយព្រឹកពេញនៅថ្ងៃទី១១ខែវិច្ឆិកាឆ្នាំ២០១៥ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អៀង មូលី** ទេសរដ្ឋមន្ត្រីនិងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដោយមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ប្រធានលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្តទាំង២៥ និងដៃគូអភិវឌ្ឍន៍ រួមទាំងសង្គមស៊ីវិល សរុបចំនួន ១២០រូប។

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២បានដំណើរការស្របតាមអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០ ០៦ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងប្រកបដោយការចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ដ៏ទូលំទូលាយ ហើយបានសម្រេចចិត្តដូចតទៅៈ

១. ផែនការយុទ្ធសាស្រ្តជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតប ទៅនឹងមេរោគអេដស៍/ជំងឺអេដស៍លើកទី៤ឆ្នាំ២០១៥-២០២០ គឺជាយុទ្ធស្រ្តជាតិតែមួយគត់ត្រូវបានប្រើប្រាស់សម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

២. កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ បានសម្រេច នូវជំហានដែលត្រូវអនុវត្តដូចខាងក្រោមៈ

ក. អ.ជ.ប.ជ.អ នឹងរៀបចំផែនការ៣ឆ្នាំរំកិលជាមួយតម្រូវការថវិកាចំណាយ និងពិនិត្យរកលទ្ធភាពធ្វើការសិក្សាអំពីសេណារីយោវិនិយោគក្នុងការងារអេដស៍ឆ្ពោះទៅកាន់ការបិទបញ្ចប់ការរីករាលដាលមេរោគអេដស៍ឲ្យបានមុនឆ្នាំ២០៣០។

ខ. អ.ជ.ប.ជ.អ ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងរៀបចំការកែសម្រួលនីតិវិធីផ្តល់ប័ណ្ណក្រីក្រដោយគិតគូរពីបញ្ហាអេដស៍។

គ. អ.ជ.ប.ជ.អក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងរៀបចំបង្កើតកូដថវិកាការងារអេដស៍នៅថ្នាក់ឃុំសង្កាត់។

ឃ. អ.ជ.ប.ជ.អ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និង ក្រសួងសុខាភិបាល ពិនិត្យលទ្ធភាពក្នុងការបង្កើន ការវិនិយោគថវិកាជាតិក្នុងការឆ្លើយតបមេរោគអេដស៍/ជំងឺអេដស៍។

ង. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបន្តជំរុញការអនុវត្តប្រ កាសលេខ ០៨៦ក.ក.ប.វ/ប្រ.កចុះថ្ងៃទី០៣ខែឧសភាឆ្នាំ២០០៦ស្តីពីការបង្កើតគណៈកម្មការ អេដស៍នៅតាមសហគ្រាសគ្រឹះស្ថាននិងការ បង្ការទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍នៅកន្លែងធ្វើការនិងប្រកាសលេខ១៩៤ ក.ប/ប្រ.កចុះថ្ងៃទី២០ខែសីហាឆ្នាំ២០១៤ស្តីពីលក្ខខណ្ឌការងារវិធាន អនាម័យនិងសន្តិសុខការងារនៃសហគ្រាសគ្រឹះស្ថានក្រុមហ៊ុនផ្នែកសេវាកម្សាន្ត។

ច. អ.ជ.ប.ជ.អ ក្រសួងសុខាភិបាល អាជ្ញាធរខេត្តជាប់ព្រំដែនកម្ពុជា–ថៃ (ខេត្តបន្ទាយមានជ័យខេត្តឧត្តរមានជ័យ ខេត្តប៉ៃលិន ខេត្តកោះកុង និងខេត្តដទៃផ្សេងទៀត)ពិនិត្យលទ្ធភាពធ្វើកិច្ចសហប្រតិបត្តការឆ្លើយតបមេរោគអេដស៍ក្នុងចំណោមប្រជាជនចំណាកស្រុក។

ឆ. មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែកនិងកាមរោគនឹងអនុវត្តវិធីសាស្ត្រ ប្រើប្រាស់ធនធានដើម្បីលទ្ធផលក្នុងការសម្រេចគោលដៅ៩០–៩០–៩០។

ជ. គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តសៀមរាបនិងខេត្តបាត់ដំបងនឹងអនុវត្ត គម្រោងសាកល្បងដើម្បីសម្រេចគោលដៅ៩០-៩០-៩០។

ឈ. អ.ជ.ប.ជ.អ ក្រសួងមហាផ្ទៃ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងព័ត៌មាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្តោតការជំរុញឲ្យបានខ្លាំងក្លានូវការអនុវត្តកម្មវិធីបង្ការការប្រើប្រាស់ គ្រឿងញៀននិងការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមយុវជន។

ញ. បន្តអនុវត្តគោលនយោបាយប្រាំពីរចំណុច តាមសារាចរលេខ២០៤៨សជណ ចុះថ្ងៃទី១៧ខែធ្នូ ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជា។

កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៥បាន សម្រេចប្រគល់ភារកិច្ចជូនអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីដឹកនាំគ្រប់គ្រង សម្របសម្រួល អនុវត្តនូវការសម្រេចចិត្តនេះ ឲ្យមានប្រសិទ្ធភាពដើម្បីឆ្ពោះទៅសម្រេចបានជោគជ័យនូវ "គោលដៅ៩០-៩០-៩០៖១)៩០% នៃមនុស្សទាំងអស់ដែលមានផ្ទុកមេរោគអេដស៍បានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ពួកគេ ២)៩០ %នៃអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ដែលបានធ្វើរោគវិនិច្ឆ័យបានបន្តទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ជាប់ជាប្រចាំ៣)៩០%នៃមនុស្សទាំងអស់ដែលទទួលព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍នឹងត្រូវរកឃើញថាបានកម្ចាត់មេរោគអេដស៍ពីក្នុងឈាមរបស់ខ្លួន"៕

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥